# វិចារណកថា

ដោយ មីស្ហែល ឫទ្ធី អង់តែល្ម

**សិក្សាចក្រ** ជាចំណងជើងនៃព្រឹត្តិប័ត្ររបស់មជ្ឈមណ្ឌលខេមរសិក្សា ។ ឈ្មោះនេះមកពីភាសាសំស្ក្រឹត ។ “សិក្សា” គឺការរៀន និង “ចក្រ” គឺ កង់, មណ្ឌល, រង្វង់មូល, ប្រទេស, អាណាខេត្ត, ពួក, ហ្វូង ។ ម្ល៉ោះហើយ យើងអាចយល់ន័យថា “កង់ ឬ វិស័យនៃការសិក្សា” ។

ចំណែកឯ **មជ្ឈមណ្ឌលខេមរសិក្សា** វិញ ឈ្មោះនេះជាសមាសនាមដែលមានទាំងពាក្យបាលី ខ្មែរ និងសំស្ក្រឹត ហើយនៅក្នុងនេះមានពាក្យថា “ខេមរៈ” ដែលតាមពិតជាពាក្យដែលខ្មែរបានច្នៃប្រឌិត ហើយដែលគេនិយមប្រើជាពាក្យអក្សរសាស្ត្រ ឬ ពាក្យសម្រាប់កវីនិពន្ធន៍ ។ អ្នកខ្លះបានយល់ថា ប្រហែលមកពីបាលី “**ខេមរោ**” (មនុស្សមានសេចក្ដីក្សេម) ដោយច្រឡំភ័ន្តនឹងពាក្យភាសាសៀម ។ ពាក្យថា “ខ្មែរ” ជាពាក្យដែលបានមកពីអម្បូរភាសាមន-ខ្មែរ ហើយសៀមបានយកពាក្យនេះទៅ សម្រាប់ហៅជនជាតិខ្មែរ ។ តែដោយហេតុថាក្នុងអក្ខរក្រមសៀម គ្មានព្យញ្ជនៈផ្ញើជើង សៀមសរសេរថា **เขมร** (ខេមរ) តាមអក្ខរាវិរុទ្ធរបស់ខ្មែរយើង ហើយបញ្ចេញសម្លេងថា ខៈម៉ែន តាមក្បួនសូរសម្លេងភាសាខ្លួន ។ ខ្មែរខ្លះ កាលណាឃើញសរសេរពាក្យនេះ ក៏ច្រឡំ ហើយសរសេរជាអក្សរខ្មែរវិញថា ខេមរៈ អានថា ខេម៉ៈរ៉ៈ ឬ ខៃម៉ៈរ៉ៈ តាមក្បួនសូរស័ព្ទបាលីក្នុងភាសាខ្មែរ ។ ក៏ប៉ុន្តែ ការណ៍ដែលយើងខ្ញុំដាក់ឈ្មោះនេះឲ្យមជ្ឈណ្ឌលយើងខ្ញុំ ក៏ល្អម៉្យាងដែរ ព្រោះវាសឲ្យឃើញថា ជាឈ្មោះដែលធ្វើពីពាក្យច្រើនភាសា ហើយទោះជាឧទ្ទិសទៅលើវប្បធម៌ខ្មែរ ដែលមិនបានញញើតទទួលឥទ្ធិពលពីបរទេសក៏ដោយ ក៏មជ្ឈមណ្ឌលយើងខ្ញុំមានគោលបំណងស្រាវជ្រាវវប្បធម៌ដទៃនៅអាស៊ីអាគ្នេយ៍ដែរ ។

មជ្ឈមណ្ឌលថ្មី ១ កំពុងកើតឡើង ។ វាមានផលប្រយោជន៍អ្វី កាលបើយើងឃើញថា មានបុគ្គលនិងស្ថាប័នជាច្រើនហើយ ដែលបានយកចិត្តទុកដាក់យ៉ាងសក្តិសិទ្ធិក្នុងការជួយស្ដារប្រទេសកម្ពុជា ទោះជាមានការលំបាកយ៉ាងណាក៏ដោយ ក្រោយពីវិនាសកម្មដែលកើតមកអំពីចម្បាំងរាំងជលជាច្រើនទសវត្សរ៍មកហើយ ? មនុស្សខ្លះអាចមានការសង្ស័យថា វាមុខជានឹងធ្វើសកម្មភាពដែលអ្នកដទៃកំពុងធ្វើរួចហើយ ឬទេ ? ហើយគេអាចសង្ស័យថា បើសិនជាមានស្ថាប័នថ្មី ១ ទៀត វាអាចនឹងធ្វើឲ្យបែកខ្ញែកនូវសមត្ថកិច្ចរបស់ជនជាតិខ្មែរនិងជនជាតិបរទេស ដ៏មានចិត្តមុតនិងយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការបណ្ដុះបណ្ដាលវរជនខ្មែរជំនាន់ក្រោយ ។ ក្នុងវិស័យវិទ្យាសាស្ត្រសង្គមនិងមនុស្សសាស្ត្រ ឬទេ ?

ក្នុងអត្ថបទរបស់បណ្ឌិត ហ្វីលីព្ពុ ប៊ីកាំ ដែលជាប្រវត្តិវិទូខាងអាស៊ីអាគ្នេយ៍ និងជានាយកស្ដីទីនៃមជ្ឈមណ្ឌល លោកបានធ្វើការរៀបរាប់អំពីប្រវត្តិនៃគម្រោងការបង្កើតមជ្ឈមណ្ឌល និងលក្ខណៈពិសេសរបស់វា ដែលជាស្ថាប័នដែលឧទ្ទិសទៅលើសហប្រតិបត្តិការអន្តរជាតិ ក្នុងវិស័យវិទ្យាសាស្ត្រសង្គមនិងមនុស្សសាស្ត្រ ដែលទាក់ទងទៅនឹងការសិក្សាខ្មែរ ។ ពាក្យគន្លឹះ គឺ ការស្រាវជ្រាវ ការបង្រៀន សេវាសាធារណៈ បណ្ណាល័យជាទីកន្លែងប្ដូរផ្ដោះរវាងស្ថាប័ន និងអ្នកស្រាវជ្រាវ និងនិស្សិតខ្មែរនិងបរទេស ដែលធ្វើការសិក្សាអំពីវប្បធម៌ខ្មែរនិងវប្បធម៌អាស៊ីអាគ្នេយ៍ទាំងឡាយ និងអង្គភាពសម្រាប់ឧបត្ថម្ភនិស្សិតខ្មែរនិងបរទេស ។ល។

ព្រឹត្តិប័ត្រនេះជាឧបករណ៍ដ៏សំខាន់បំផុតសម្រាប់មជ្ឈមណ្ឌលយើងខ្ញុំ ។ នាទីរបស់វា គឺរៀបរាប់អំពីសកម្មភាពរបស់មជ្ឈមណ្ឌល ជាពិសេសអំពីការស្រាវជ្រាវរបស់សមាជិក ដែលនឹងបោះពុម្ពជាអត្ថបទនិងសេចក្ដីសង្ខេប ។ ក៏ប៉ុន្តែ ការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវ គ្រាន់តែជាចំណុចតូចមួយ ពីព្រោះព្រឹត្តិប័ត្រ និង ទស្សនាវដ្ដីដែលមានគុណភាពខាងវិទ្យាសាស្ត្រ មានស្រាប់ ឬ កំពុងតែបង្កើតសព្វថ្ងៃនេះ នៅប្រទេសកម្ពុជានិងបរទេស ។ តាមពិត គោលដៅសំខាន់ គឺសម្រាប់ជាទីកន្លែងជួបគ្នាសម្រាប់និស្សិតនិងអ្នកស្រាវជ្រាវកម្ពុជា ជាមួយនឹងប្រទេសឯទៀត ដែលមាន ការសិក្សាក្នុងវិស័យខ្មែរ ដោយជួយជម្រាបនិស្សិតខ្មែរឲ្យដឹងអំពីការបង្រៀន និងការស្រាវជ្រាវនៅបរទេស និងជម្រាបជនបរទេសដែលចាប់អារម្មណ៍នឹងវិស័យខ្មែរ ឲ្យដឹងអំពីអ្វីដែលកំពុងតែធ្វើនៅប្រទេសកម្ពុជាផ្ទាល់ ។

នៅទីកន្លែង មជ្ឈមណ្ឌលនឹងយកអគារចំនួនពីរឬបីខ្នង ដែលស្ថិតក្នុងវត្តអារាម ១ មកប្រើប្រាស់ជាទីកន្លែងបង្រៀនវិជ្ជាតម្រិះ ដោយមូលហេតុថា វត្តអារាម នៅក្នុងប្រទេសដែលកាន់ព្រះពុទ្ធសាសនាថេរវាទនៅជ្រោយឥណ្ឌូចិន មានទម្លាប់យកធ្វើជាទីកន្លែងសម្រាប់រៀនសូត្រ ។ លោក ប្រ៊ង់ស្វា តាំងទុយរីយ៉េ សមាជិករបស់មជ្ឈមណ្ឌល ដែលជាស្ថាបត្យករ-នគរូបនីយករ ជូនអត្ថបទរាយការណ៍អំពីការងារជួសជុលស្ដារសាលារៀន ២ ខ្នង ដែលស្ថិតក្នុងវត្តដំណាក់ ។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះគាត់ ដែលបានគូរច្នៃកាឡៃក្នុងកុំព្យូទ័រយូរ ដោយប្រើពេលវេលាយ៉ាងយូរ នូវក្បាច់ហោជាងនៃសាលាពុទ្ធិកបឋមសិក្សារបស់វត្តដំណាក់ ដែលគេលែងប្រើប្រាស់តាំងពីជំនាន់ខ្មែរក្រហម ហើយដែលជាអគារ ១ ដែលយើងខ្ញុំបានជ្រើសរើសសម្រាប់តាំងបណ្ណាល័យ ។ គំនូរនេះ មានដាក់ក្នុងក្របខាងមុខនៃព្រឹត្តិប័ត្រ ។ ជំនួយការគាត់ គឺ អ្នកស្រី ជាម ផល្លី ដែលជាស្ថាបត្យករ បានសរសេរអត្ថបទ ១ ដែលរៀបរាប់អំពីប្រវត្តិរបស់វត្តដំណាក់ និងជាពិសេសរបស់អគារដែលបានចាប់ផ្ដើមជួសជុល ។

លោក វិល្មៀម សោធរវីរ៍ធ សមាជិករបស់មជ្ឈមណ្ឌល ដែលជាបុរាណវិទូមានឯកទេសខាងចម្ប៉ា បានសរសេរអំពីស្ថានភាពបុរាណវិទ្យានៅប្រទេសកម្ពុជា ។ ហើយនៅក្នុងព្រឹត្តិប័ត្រនេះ ជាទីបញ្ចប់ ក៏មានការរៀបរាប់អំពីព្រឹត្តិការណ៍វប្បធម៌ខ្លះ ដែលមាននៅប្រទេសកម្ពុជា អស់ប៉ុន្មានខែកន្លងមកនេះ ។

យើងខ្ញុំសង្ឃឹមថា ព្រឹត្តិប័ត្រសិក្សាចក្រអាចមានសារៈសំខាន់ក្នុងចំណោមសៀវភៅ ព្រឹត្តិប័ត្រ និងទស្សនាវដ្ដី ស្ដីអំពីសិក្សាខ្មែរ ហើយនិងមានផលប្រយោជន៍ដល់អ្នកនិយមនិងស្រាវជ្រាវអំពីវប្បធម៌ខ្មែរ ហើយជាពិសេស ដល់ជនជាតិខ្មែរ ដែលឧទ្ទិសទៅលើការសិក្សានិងការស្ដារវប្បធម៌ខ្លួន ៕